# ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល

## ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៤៥

ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០៤

សាលដីកា

លេខ : ២៧៦

ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៤

## គាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាព ដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២- លោក | ប្រាក់ | គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៣- លោក | ជីវ | កេង | ជាចៅក្រម |
| ៤- លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥- លោក | គង់ | ភីរុន | ជាចៅក្រម |

ក្រឡាបញ្ជី

កញ្ញា ធន់ វណ្ណធឿន

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៥០ " ឈ " ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៦២២ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាង :

- ដើមចោទឈ្មោះ ខេង ម៉ី ដើមបណ្តឹងសាទុក្ខ ភេទស្រី អាយុ ៤៦ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ភូមិកំពង់បាយខាងជើង ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ។ ឪពុកឈ្មោះ ខេង ហ៊ុយ

"ស" ម្ដាយឈ្មោះ លឹម ស៊ី "ស" ប្ដីឈ្មោះ ថៃ ប៉ាវ មានកូន ៣ នាក់ ។

មានមេធាវី លោក កើត វណ្ណរិទ្ធិ

- និងចុងចម្លើយ ឈ្មោះ លី ជិនលី ចុងបណ្ដឹងសាទុក្ខ ភេទប្រុស អាយុ ៤៨ ឆ្នាំ ជាតិ ខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ភូមិកំពង់បាយខាងជើង ឃុំកំពង់បាយ ស្រុកកំពង់បាយ ខេត្តកំពត ។ ឪពុកឈ្មោះ លី ស៊ាង "រ" ម្ដាយឈ្មោះ ខូវ យូ "ស" ប្រពន្ធឈ្មោះ លី លី មានកូន ២នាក់ ។

មានមេធាវី លោក កែវ យ៉ា និង លោក ឯល វណ្ណៈ

អំពីវិវាទ : ប្ដឹងមិនឱ្យជាប់សសរ និង ជញ្ជាំង , ទាមទារថ្លៃជញ្ជាំង ៤ម ×១២មចំនួន៥០០$US

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៥ ចុះថ្ងៃទី ០៥ខែ កក្កដា ឆ្នាំ ២០០៤ របស់តុលាការ-កំពូល ។

បានឃើញបណ្ដឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ របស់អ្នកស្រី ខេង ម៉ី ( ទទួលពាក្យបណ្ដឹងសាទុក្ខ ចុះថ្ងៃទី ៩-៦-២០០៤ ). មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៥០ "ឈ" ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សេចក្ដីសំរេចទាំងមូល ។

តាមពាក្យបណ្ដឹង របស់ដើមចោទឈ្មោះ ខេង ម៉ី ថា កន្លងមកឈ្មោះ លី ជិនលី បានទំនាក់ទំនងជាមួយមេឃុំឱ្យមកទំនាក់ទំនងជាមួយខ្លួន ដើម្បីសង់ផ្ទះបន្ត ។ ខណៈនោះ មេឃុំមិនបានរៀបរាប់ពីការសាងសង់ឱ្យបានច្បាស់លាស់ទេ ប្ដីខ្លួនក៏បានផ្ដិតមេដៃឱ្យនៅលើកិច្ចសន្យាជាប់ព្រំឱ្យទៅ ។ លុះដល់ពេលសាងសង់ទើបដឹងថា ត្រូវជាប់សសរ និង ជាប់ជញ្ជាំងខ្លះៗ ពេលនោះខ្លួនបានជំទាស់ឡើងដោយយល់ឃើញថា ខឿន គ្រឹះមិនរឹងមាំ មិនអាចធានាសុវត្ថភាពបាន។ ទើបពេលនេះ ខ្លួនសុំប្ដឹងហាមឃាត់មិនឱ្យសាងសង់បន្តទៅជាន់លើ ម្យ៉ាងទៀតប្រើជញ្ជាំងប៉ុណ្ណា ត្រូវគិតលុយប៉ុណ្ណឹង និង ទាមទារ ថ្លៃជញ្ជាំងផ្ទះខាងក្រោយ ជាន់ក្រោម ទទឹង ៤ម ×បណ្ដោយ ១២ម ចំនួន ៥០០ ដុល្លារអាមេរិក ព្រោះជញ្ជាំងទាំងនោះ ខ្លួនជាអ្នកសាងសង់ ។

តាមពាក្យបណ្ដឹងសារត្រឡប់របស់ឈ្មោះ លី ជិនលី ថា : កន្លងមកឈ្មោះ ថៃ ប៉ាវ បានសង់ផ្ទះ នៅជាន់ខាងលើ ពុំមានការអនុញ្ញាតិ ហើយបានសង់រំលោភបំពានលើខឿន អឡុសិទ្ធិចូលមកខាងខ្លួន ។ ពេលនេះ ខ្លួនត្រូវសាងសង់បន្ត ដោយមានការអនុញ្ញាតិគ្រប់គ្រាន់ និង មានការយល់ព្រមពី ថៃ ប៉ាវ ផងដែរ ។ នៅពេលចាប់ដំណើរការសាងសង់ ស្រាប់តែឈ្មោះ ថៃ ប៉ាវ បែរជាជំទាស់មិនឱ្យសាងសង់ទៅវិញ ដោយប្ដឹងទៅតុលាការឱ្យផ្អាកការសាងសង់របស់ខ្លួន ។

ដូច្នេះទើបពេលនេះ ខ្លួនប្ដឹងតបសុំឱ្យ ថៃ ប៉ាវ រុះរើសសរ និង ជញ្ជាំងចេញពីលើថ្នឹមរបស់ខ្លួន និងសុំសាងសង់ផ្ទះបន្តទៀត ។

បានឃើញ ដីកាសំរេចតាមពាក្យសុំ លេខ ២៥២ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពត ដែលសំរេច ៖

១- ទទួលពាក្យបណ្ដឹងសុំរបស់ឈ្មោះ ខេង ម៉ី ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ហាមឃាត់រាល់សកម្មភាពរបស់ឈ្មោះ តាំង ជិនលី ដែលធ្វើឱ្យប៉ះពាល់ដល់ជញ្ជាំងផ្ទះរបស់ឈ្មោះ ខេង ម៉ី ជាន់ខាងលើ ដែលខ័ណ្ឌផ្ទះឈ្មោះ ខេង ម៉ី និង ផ្ទះឈ្មោះ តាំង ជិនលី ដោយឱ្យរក្សាទុកភាពដើមសិនរង់ចាំតុលាការសំរេចដល់រឿងអង្គសេចក្ដី ។

៣- បង្គាប់មកលោក អធិការនគរបាល ស្រុកកំពង់បាយ និង អាជ្ញាធរមូលដ្ឋាន អនុវត្តដីកានេះឱ្យបានសំរេច ចាប់ពីពេលនេះតទៅ ។

ដីកាសំរេចនេះ មានប្រសិទ្ធិភាពអនុវត្តភ្លាមៗ បើភាគីណាមួយមិនសុខចិត្ត និង ដីកាសំរេចនេះ មានសិទ្ធិចូលមកប្ដឹងជំទាស់នៅតុលាការសាម៉ី កំណត់រយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃបានទទួលដីកានេះតទៅ ។

បានឃើញបណ្ដឹងទាស់ របស់លោក លី ជិនលី ប្ដឹងមិនសុខចិត្តនឹងដីកាសំរេចតាមពាក្យសុំលេខ ២៥២ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពត ទាំងមូល ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពត ដែលមានខ្លឹមសារ នៃ សេចក្ដីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្ដឹងរបស់នារី ខេង ម៉ី ចុះថ្ងៃទី ២៣-៤-២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ តែបដិសេធចោលដោយទាស់នឹង គតិច្បាប់ ។

២- ទទួលពាក្យបណ្ដឹងតបរបស់ឈ្មោះ លី ជិនលី ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៣ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- អនុញ្ញាតឱ្យឈ្មោះ លី ជិនលី សាងសង់បន្ត តាមលិខិតអនុញ្ញាតសាងសង់លេខ ១៧៩ អនញ របស់អភិបាលខេត្តកំពត តាមប្លង់សាងសង់ភ្ជាប់មកជាមួយ តាមបច្ចេកទេសរបស់ជំនាញ ដោយរុះរើសសរ ៣ដើម និង ជញ្ជាំង ដែលធ្វើខុសបច្ចេកទេសចេញ ហើយរៀបសារជាថ្មីតាមបច្ចេកទេស ដើម្បីទ្រកំពស់ និង ទម្ងន់បាន គឺជាជញ្ជាំងអឡូសិទ្ធិ រវាងឈ្មោះ លី ជិនលី និង នារី ខេង ម៉ី ចាប់ពីពេលនេះតទៅ ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដី ៧.០០០រៀល ដែលនារី ខេង ម៉ី បានបង់ទុករួចហើយ ដើម្បីចាត់ចែងតាមច្បាប់ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈប្រកាសជាសាធារណៈចំពោះមុខគូក្ដី សំរេចបើកផ្លូវឧទ្ធរណ៍ រយៈពេល ២ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៣ របស់អ្នកស្រី ខេង មុី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពត លើសាលក្រមទាំងមូល និង បណ្តឹងឧទ្ធរណ៍លេខ ៥៧ ចុះថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៣ របស់លោក លី ជិនលី ប្តឹងមិនសុខចិត្ត លើត្រង់ចំណុច មិនបានសំរេចអំពីសំណងជម្ងឺចិត្ត ។

បានឃើញ សាលដីការបៀបលេខ ៤ " ឈ " ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេច ដូចតទៅ :

១- ចាត់របៀបឱ្យស្ថាប័នជំនាញចុះអង្កេតធ្វើការវាយតំលៃលើការខូចខាតផ្ទះរបស់ដើមចោទឈ្មោះ ថៃ ប៉ាវ និង ប្រពន្ធឈ្មោះ ខេង មុី ជាមុនសិន មុននឹងសំរេចដល់អង្គសេចក្តី ។ ក្នុងករណីចាំបាច់សាលាឧទ្ធរណ៍នឹងចុះពិនិត្យដល់ទីកន្លែងផ្ទះទំនាស់ ។

២- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និង មេធាវីតំណាងចុងចម្លើយ ។

បានឃើញ សាលដីការដ្ឋប្បវេណី លេខ ៥០ " ឈ " ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២២-៨-២០០៣ របស់ឈ្មោះ ខេង មុី ទុកជាត្រឹមត្រូវតាមទំរង់ ច្បាប់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៥-៩-២០០៣ របស់ឈ្មោះ លី ជិនលី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

៣- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១២១ ចុះថ្ងៃទី ១៧-៧-២០០៣ របស់តុលាការខេត្តកំពតទុកជាបានការដដែល ។

៤- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ គឺ ពន្ធហ្លឹង និង ពន្ធចុះបញ្ជីក្តី ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ និង អាជ្ញាធរតុលាការ ១០.០០០រៀល សរុប ១៣.០០០រៀល ។

៥- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២៧-០៤-២០០៤ ចំពោះមុខគូក្តី តែទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ របស់ អ្នកស្រី ខេង មុី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៥០ " ឈ " ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍លើត្រង់ចំណុច នៃ សេចក្តីសំរេច ទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ របស់អ្នកស្រី ខេង ម៉ី

បានឃើញ សារណាតប ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៤ របស់ លោក លី ជិនលី

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ របស់ដើមចោទស្ថិតក្នុងកំណត់ច្បាប់ ។

- សាលដីការដ្ឋប្បវេណីលេខ ៥០ " ឈ " ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេច ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ខេង ម៉ី បានឆ្លើយថា : បានជាខ្លួនប្តឹងមិនសុខចិត្តនេះ ពីព្រោះផ្ទះខ្លួន ពេលសាងសង់នោះ គឺ ស្រុកជាអ្នកម៉ៅការជាង ដោយសង់ពីមុខដល់ក្រោយ ពីក្រោមដល់លើ ប្រវែង១៦ម មួយជាន់កន្លះ ជាន់ទីមួយចាក់ប្លង់សេទាំងអស់ ឯជាន់ទីពីរ ចាក់ប្លង់សេតែ ៤ម និង ១២ម ទៀត ប្រក់សង្កសីនិងជាន់ក្រោមតទៅ១២ម ទៀត ។ ឯផ្ទះរបស់លោក លី ជិនលី វិញ ពេលនោះសង់តែ ៤ម ទេ លុះដល់៣ឆ្នាំក្រោយមក លោក លី ជិនលី ក៏បានសាងសង់ ១២ម កំពស់ ៤ម ទៀត ដោយប្រើជញ្ជាំងផ្ទះរបស់ខ្លួន គាត់បានឱ្យលុយថ្លៃជញ្ជាំងនេះរួចហើយ ប៉ុន្តែនៅតែថ្លៃជញ្ជាំងក្រោយបំផុតប្រវែង ១២ម កំពស់ ៤ម មិនទាន់ឱ្យលុយទេ ប្រើអស់រយៈពេល ៧ឆ្នាំ មកហើយ ដោយពឹងផ្អែកលើជញ្ជាំងផ្ទះរបស់ខ្លួនទាំងស្រុង ។ រឿងទំនាស់គ្នានេះ មកពីលោក លី ជិនលី មកវាយជញ្ជាំង និង ជាប់សសរផ្ទះខ្លួន ប៉ុន្តែពុំទាន់មានការសាងសង់ផ្ទះទេ ។ ចំណែករឿងប្តឹងផ្តល់នេះ ខ្លួនមិនហ៊ានប្តឹងហាមឃាត់មិនឱ្យសាងសង់ទេ គឺគ្រាន់តែការសាងសង់នេះ សូមឱ្យមានអ្នកជំនាញត្រឹមត្រូវ ដើម្បីការពារសុវត្ថិភាព និង សូមទាមទារថ្លៃជញ្ជាំង ៤ម × ១២ម ចំនួន ៥០០ដុល្លាអាមេរិក ។

ក្រឡាបញ្ជីអានសារណារបស់លោក លី ជិនលី

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក កើត វណ្ណរិទ្ធ ការពារឱ្យដើមចោទ បញ្ជាក់ថា :

នៅមុនឆ្នាំ ១៩៩០ អាជ្ញាធរស្រុកបានណែនាំដល់ប្រជាជនដែលនៅជុំវិញផ្សារ ជូរមុខ ឱ្យសង់ផ្ទះថ្ម ដោយមានសិទ្ធិសង់ ទទឹង ៤,២ម × ២១ម កំពស់ ២ជាន់ ដោយមិនគិតជាន់ផ្ទាល់ដី បើគ្មានលទ្ធភាពទេ យ៉ាងហោចណាស់ក៏សង់បាន ៤ម ដំបូលប្រក់សង្កសីដែរ ដើម្បីជៀសវៀងអគ្គីភ័យញឹកញាប់ ។ ហើយក្រោយមកលោក លី ជិនលី បានមកសុំកូនក្តីខ្លួន ដើម្បីសាងសង់បន្តលើកទី១ គាត់បានឱ្យថ្លៃជញ្ជាំងរួចហើយ តែដល់សុំសង់បន្តជាលើកទី២ គាត់ពុំបានចេញថ្លៃជញ្ជាំងឱ្យកូនក្តីខ្លួន ដោយប្រើអស់រយៈពេល ៧ឆ្នាំ កន្លងមកហើយ ។ លុះមកដល់ថ្ងៃទី ១៦-៣-២០០៣ មានតាចាំវម្នាក់ធ្វើការនៅឃុំ បានមកទំនាក់ទំនងឱ្យកូនក្តីរបស់ខ្លួនចុះកិច្ចសន្យាជាប់ព្រំ ការចុះកិច្ចសន្យាយល់ថា មានលំនាំដូចផ្ទះកូនក្តីខ្លួនដែរ ហើយនឹងប៉ះប៉ូវគ្នាតាមតំលៃសមស្រប ។ លុះដល់រសៀលថ្ងៃ

ទី ២២-៤-២០០៣ លោក លី ជិនលី បានមកសុំសសរបីដើម ជញ្ជាំងបីចន្លោះ ដើម្បីវាយចោល ហើយធ្វើសារជាថ្មី ពេលនោះ កូនក្ដីរបស់ខ្លួន ពុំបានយល់ព្រមទេ គឺសុំបដិសេធរួចទៅហើយ ហើយគាត់ក៏ពុំបានប្ដឹងហួសកំណត់ថ្ងៃប្ដឹងបដិសេធដែរ ប៉ុន្តែលោក លី ជិនលី បែរជាមកដាប់សសរដោយរំលោភបំពាន ។ ទង្វើរបស់លោក លី ជិនលី មានរួចទៅហើយ ទើបកូនក្ដីរបស់ខ្លួនរត់ទៅរកតុលាការជាក្រោយ ដោយជញ្ជាំងនេះ វាជាជញ្ជាំងអឡុសិទ្ធិ ហើយកូនក្ដីរបស់ខ្លួនមានការអត់ធ្មត់ណាស់ ពេលលោក លី ជិនលី មករំលោភដិសសរផ្ទះ កូនក្ដីរបស់ខ្លួនបានរត់ចូលទៅក្នុងផ្ទះសំង៉ ។ កូនក្ដីរបស់ខ្លួនមិនសំណូមពរអ្វីច្រើនពេកទេ គឺគ្រាន់តែសំណូមពរ :

- បើលោក លី ជិនលី ចង់សាងសង់ផ្ទះ គឺត្រូវមានអ្នកជំនាញ
- កូនក្ដីរបស់ខ្លួន សុំឱ្យលោក លី ជិនលី ត្រូវទទួលខុសត្រូវនៅពេលផ្ទះមានការបាក់ស្រុត
- សុំទាមទារថ្លៃជញ្ជាំងចំនួន ៥០០ ដុល្លា អាមេរិក

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី លោក កែវ យ៉ា ការពារឱ្យចុងចម្លើយ បញ្ជាក់ថា :

ទាក់ទងនឹងរឿងកូនក្ដីរបស់ខ្លួន គឺអ្នកស្រី ខេង ម៉ី គាត់ថា មិនជំទាស់ទេ ក្នុងការសាងសង់ និងទាមទារឱ្យសង់អ្វីដែលខុសពីស្លឹក ដើម្បីជៀសវៀងការឆេះផ្ទះញឹកញាប់ ពីព្រោះ បើកូនក្ដីរបស់ខ្លួនសង់ផ្ទះ ពុំបានប្រើជញ្ជាំងអឡុសិទ្ធិទេ ជញ្ជាំងរបស់កូនក្ដីខ្លួននោះក៏មានដែរ ដោយពុំបានប្រើជញ្ជាំងរបស់អ្នកស្រី ខេង ម៉ី ទេ ។ ការផ្ដិតមេដៃនៅចំពោះមុខលោកមេឃុំ ហើយប្ដីប្រពន្ធត្រូវតែសំរេចគ្នារួចហើយ ក្នុងការផ្ដិតមេដៃនេះ ។

- បើសិនជាមានការបាក់ស្រុតផ្ទះនោះ កូនក្ដីរបស់ខ្លួនជាអ្នកចេញសង លុះត្រាតែកូនក្ដីរបស់ខ្លួនបានសាងសង់ដោយពឹងផ្អែកលើផ្ទះរបស់អ្នកស្រី ខេង ម៉ី ។
- ចំណែកជញ្ជាំងអឡុសិទ្ធិ កូនក្ដីរបស់ខ្លួន បានធ្វើឱ្យវិញហើយអស់ប្រហែល ២០ ដុល្លាអាមេរិក ។
- ចំពោះការទាមទារប្រាក់ ៥០០ដុល្លាអាមេរិក ថ្លៃជញ្ជាំងអឡុសិទ្ធិនេះមិនត្រឹមត្រូវទេ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី លោក ឯល វណ្ណៈ ការពារឱ្យចុងចម្លើយ បញ្ជាក់ថា :

ខ្លួនសូមលើកឡើងពីសំណង់ គឺការសាងសង់របស់អ្នកស្រី ខេង ម៉ី មិនត្រឹមត្រូវទេ ពីព្រោះគាត់សាងសង់ដោយខ្លួនឯង គ្មានអាជ្ញាធរណាចុះត្រួតពិនិត្យទេ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី លោក កើត វណ្ណរិទ្ធិ ការពារឱ្យដើមចោទ បញ្ជាក់បន្ថែមទៀតថា : ការសាងសង់នេះ កូនក្ដីរបស់ខ្លួនបានធានាតែល្វែងលើ ឯល្វែងក្រោមមិនទទួលខុសត្រូវទេ ។ លោកលី ជិនលី មានភ័ព្វវាសនាល្អណាស់ ដែលរួចផុតពីទោសព្រហ្មទណ្ឌ គឺគ្រាន់តែសងថ្លៃការខូចខាត តែប៉ុណ្ណោះ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី លោក កែវ យ៉ា ការពារឱ្យចុងចម្លើយ បញ្ជាក់បន្ថែមទៀតថា : គ្មានលក្ខខណ្ឌណាឱ្យសង់តែ ៤ម៉ែទេ គឺស្រុកជាអ្នកកំណត់ឱ្យសង់ ៣ជាន់ នៅជុំវិញផ្សារសាមគ្គី ហើយ

ការសាងសង់ ១ជាន់កន្លះនោះ វាខុសតាមស្តង់ដាហើយ ។

បានស្តាប់ចម្លើយរបស់ អ្នកស្រី ខេង ម៉ី បញ្ជាក់បន្ថែមទៀតថា : កាលមុនឆ្នាំ ១៩៩០ ស្រុកពុំបានប្រកាសឱ្យសាងសង់ ៣ ជាន់ទេ គឺពុំបានប្រាប់ឱ្យបុកគ្រឹះទុកសំរាប់សាងសង់ ៣ជាន់នោះទេ មានលុយប៉ុណ្ណាធ្វើប៉ុណ្ណឹងទៅ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដើមចោទ សារណាចុងចម្លើយ និង សេចក្តីសន្និដ្ឋានការពារ របស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៥-៦-២០០៤ របស់អ្នកស្រី ខេង ម៉ី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់អ្នកស្រី ខេង ម៉ី ក្នុងសារណា ចុះថ្ងៃទី ២៣-៧-២០០៤ ថា ការដែលឈ្មោះ លី ជិនលី មកវាយជញ្ជាំង និង សសរផ្ទះរបស់ខ្លួន ជាការបំពានកម្មសិទ្ធិរបស់ខ្លួននោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា តាមកិច្ចសន្យាជាប់ព្រំ ចុះថ្ងៃទី ១៦-០១-២០០៣ លោក ថៃ ប៉ាវ ប្តីរបស់អ្នកស្រី ខេង ម៉ី បានអនុញ្ញាតឱ្យលោក លី ជិនលី និង អ្នកស្រី លី លី សាងសង់ផ្ទះបន្ត មួយជាន់កន្លះជាប់ជាមួយជញ្ជាំងផ្ទះខ្លួន ដោយបង្កលក្ខណៈងាយស្រួលសព្វបែបយ៉ាង ក្នុងពេលសាងសង់ និង គ្មានទំនាស់អ្វីឡើយ ។

- យល់ឃើញថា ការដែលដើមចោទ និង មេធាវីដើមចោទ លើកឡើងនៅពេលសវនាការនេះថា កិច្ចសន្យាជាប់ព្រំ ចុះថ្ងៃទី ១៦-០១-២០០៣ ធ្វើឡើងដោយភ័ន្តច្រឡំថា ចុងចម្លើយធ្វើផ្ទះ ១ជាន់កន្លះ ដូចផ្ទះអ្នកស្រី ហើយថា អ្នកស្រីបានប្តឹងសុំមោឃៈភាពតាមមាត្រា ១៩ នៃ ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រច. ចុះថ្ងៃទី ២៨-១០-៨៨ នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ខ្លឹមសារខាងក្រោមនៃ កិច្ចសន្យានេះ បញ្ជាក់ថា ដើមចោទពុំមែនភ័ន្តច្រឡំទេ ។ ដូច្នេះ ពុំមានមូលហេតុដែលនាំឱ្យមោឃភាពកិច្ចសន្យាជាប់ព្រំនេះបានទេ ទោះបីអ្នកស្រីបានប្តឹងក្នុងកំណត់ច្បាប់ក៏ដោយ ។

៣០៧

-	យល់ឃើញថា ការលើកឡើងរបស់អ្នកស្រី ខេង មុី ថា ជើងគ្រឹះរបស់ផ្ទះខ្លួន គឺសំរាប់សង់ផ្ទះដូចផ្ទះខ្លួន ពុំអាចសង់ផ្ទះ ដូចលិខិតអនុញ្ញាតសាងសង់ របស់ស្ថាប័នមានសមត្ថកិច្ចទេ នោះ គឺ ជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

+ ក្នុងលិខិតលេខ ១៥២ ដន សស ចុះថ្ងៃទី ១៦-៥-២០០៣ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និង សុរិយោដីខេត្តកំពត និង លិខិតបញ្ជាក់ ចុះថ្ងៃទី ០៨-៥-២០០៣ របស់ប្រធានគណៈកម្មាធិការសាងសង់ផ្ទះល្វែងជុំវិញ បរិវេណផ្សារសាមគ្គី ស្រុកទឹកឈូខេត្តកំពត បានបញ្ជាក់ថា ការសាងសង់ជើងគ្រឹះផ្ទះល្វែងទាំងអស់ អនុវត្តតាមប្លង់ស្តង់ដារបស់ខេត្ត ដែលតំរូវឱ្យសាងសង់សំរាប់ទ្រទំងន់ បីជាន់កន្លះ ( គិតទាំងជាន់ផ្ទាល់-ដី ) ក្រោមការត្រួតពិនិត្យផ្នែកបច្ចេកទេស យ៉ាងត្រឹមត្រូវ ។

+ សំណង់របស់ចុងចម្លើយមានប្លង់ និង ច្បាប់អនុញ្ញាតឱ្យសាងសង់ពីស្ថាប័នមានសមត្ថកិច្ចត្រឹម-ត្រូវ ។

-	យល់ឃើញថា ការដែលដើមចោទ លើកឡើងនៅពេលសវនាការនេះ ថា អ្នកស្រី ទាមទារថ្លៃជញ្ជាំងខាងក្រោមចំនួន ៥០០ដុល្លាអាមេរិកនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះចុងចម្លើយពុំបានប្រើប្រាស់ជញ្ជាំងរបស់ដើមចោទទេ គឺ ចុងចម្លើយបានរៀបជញ្ជាំងថ្មី ។

-	យល់ឃើញថា ចុងចម្លើយបានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូល ជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-	យល់ឃើញថា សាលដីកាវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍លេខ ៥០ " ឈ " ចុះថ្ងៃទី ០៦-៥-២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ

## ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-	ទទួលបណ្តឹងសាទុក្ខលេខ ២០៤ ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៤ របស់អ្នកស្រី ខេង មុី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-	តម្កល់សាលដីកាវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍លេខ ៥០ " ឈ " ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-	រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៥.០០០រៀល ដែល លោក លី ជិនលី បានបង់ជូនសតី :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊្លឹង ចំនួន ៨០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,
- ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥០០០ រៀល សរុប ១៩០០០ រៀល ។

ហើយតំរូវឱ្យអ្នកស្រី ខេង ម៉ី សងប្រាក់ចំនួន ១៩.០០០រៀល នេះ ទៅឱ្យលោក លី ជិនលី វិញ ។

៤- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ។